ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

**សូមគោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ:** *របាយការណ៍នៃកិច្ចប្រជុំប្រចាំខែកក្កដា រវាង DICO និង ភ្នាក់ងារអនុវត្តន៍គម្រោង IAs (Implementing Agencies) ។*

**យោង:** *- ចំណាររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ថ្ងៃទី ២៨ មេសា ២០១១*
*- លិខិតអញ្ជើញរបស់ DICO លេខ: ១៦៨ ចុះថ្ងៃទី ០៧ កក្កដា ២០១១*

*តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរព និង រាយការណ៍ ជូន* **ឯកឧត្តម ទេសរដ្ឋមន្ត្រី** *មេត្តាជ្រាបថា: កាលពីថ្ងៃទី ១១ កក្កដា ២០១១ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (DICO) បានរៀបចំកិច្ចប្រជុំជាបន្ទាន់មួយប្រចាំខែកក្កដា រវាង DICO និង IAs ក្នុងគោលបំណងដោះស្រាយបញ្ហានៃការរៀបចំផែនការបណ្តុះបណ្តាល, សិក្ខាសាលា, និងទស្សនៈកិច្ចសិក្សា របស់ IAs ទាំងអស់ ដើម្បីជុំរុញការអនុវត្តន៍គម្រោង TDSP ។*

- Benchmark *នៅក្នុង* Mid Term Review *បានតម្រូវឲ្យ* DICO *និង* IAs *រៀបចំផែនការបណ្តុះបណ្តាល, សិក្ខាសាលា, និងទស្សនៈកិច្ចសិក្សា ទាំងអស់នៅក្នុងត្រីមាសទី៣ និងទី៤ ឆ្នាំ ២០១១ ហើយដាក់សុំ* NOL (No Objection Letter) *តែម្តង (មួយកញ្ចប់) ពីធនាគារពិភពលោក ។*
- *ក្រោយពីបានផ្ញើរពង្រៀងផែនការបណ្តុះបណ្តាលនេះ ទៅធនាគារពិភពលោកដើម្បីពិនិត្យ ធនាគារពិភពលោកបានស្នើឲ្យយើងកែតម្រូវ និងពិភាក្សានូវចំណុចមួយចំនួន*

ហើយដែលនេះជាគោលបំណងសំខាន់ ក្នុងការរៀបចំកិច្ចប្រជុំជាបន្ទាន់នេះ ដើម្បីឆ្លើយតបទៅនឹងការស្នើរបស់ធនាគារពិភពលោក ។

- ក្រោយពីបានស្តាប់ និងពិភាក្សានូវចំណុចនានាដែលពាក់ព័ន្ធ យើងបានឯកភាពគ្នានូវចំណុចមួយចំនួន ដូចមានបរិយាយនៅក្នុង ឧបសម្ព័ន្ធទី១ និងបានយល់ព្រមរៀបចំកិច្ចសន្យារយៈពេលវែងជាមួយអ្នកផ្គត់ផ្គង់សេវាកម្មអ្នកបកប្រែប្រដេញ និងឯកសារ, សម្ភារៈជំនួយត្រចៀក, និងរថយន្តធ្វើដំណើរ ដើម្បីអនុញ្ញាតឲ្យភ្នាក់ងារអនុវត្តគម្រោងទាំងអស់អាចប្រើប្រាស់សេវាទាំងនេះ ។
- ចំណុចដែលសេសសល់ដែលធនាគារពិភពលោកត្រូវពិភាក្សាពេលក្រោយរួមមានៈ
    - អត្រាកម្រៃក្នុងការអញ្ជើញវាគ្មិនកិត្តិយសឯកជនចូលរួមបកស្រាយពិភាក្សា និងបង្រៀននៅក្នុងសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ។
    - ការចំណាយទិញអាវយឺត, មួក និងកាតាបដែលមានផ្លាកសញ្ញា Trade SWAp ដើម្បីចែកជូនសិក្ខាកាមនៅក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ។
    - ធនាគារពិពភលោកមិនអនុញ្ញាតឲ្យប្រើ Logo របស់ខ្លួននៅក្នុងសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលទេ ។
- មានតំណាងរបស់ធនាគារពីររូបបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ គឺលោក សុខ វណ្ណារ៉ា និងលោកស្រី ហេង សេដា ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។ សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ កក្កដា ២០១១

**ប្រធាននាយដ្ឋាន**

ឈៀង ពេជ្រ

<u>ចម្លងជូនៈ</u>

- ឯកឧត្តម ប៉ាន សូរស័ក្តិ
- ឯកឧត្តម ឌិត ទីណា
- ឯកឧត្តម សុខ សុភ័ក្រ្ត
- ឯកសារ - កាលប្បវត្តិ